Sustainable Development Verified Impact Standard

# គម្រោងរេដបូកជួរភ្នំក្រវាញខាងត្បូង
# ការបរិយាយសង្ខេបអំពីការតាមដាន និងការអនុវត្តគម្រោង

### រៀបរៀងដោយ សម្ព័ន្ធមិត្តសត្វព្រៃ



បរិស្ថាន

WILDLIFEALLIANCE
Direct Protection to Forests & Wildlife

គម្រោងរេដបូកជួរភ្នំក្រវាញខាងត្បូង(SCRP) ត្រូវបានផ្តួចផ្តើមរៀបចំឡើងដើម្បីជួយជំរុញឱ្យមានការកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ អភិរក្សជីវចម្រុះ និងបង្កើតឱ្យមានជម្រើសជីវភាពរស់នៅ ស្របតាមផែនការរបស់អង្គការសហប្រជាជាតិ ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដែលបណ្តាលមកពីការបាត់បង់ និងរេចរិលព្រៃឈើ (REDD+) ។ ផ្ទៃដីទីតាំងគម្រោងរេដបូកតំបន់ជួរភ្នំក្រវាញខាងត្បូងមានទំហំ ៤៩៣ ៥៨២.៦ ហិកតា ក្នុងនោះ ផ្នែកខ្លះស្ថិតនៅក្នុងឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង និងមួយផ្នែកទៀតស្ថិតក្នុងដែនជម្រកសត្វព្រៃតាតៃ ហើយនឹងផ្តល់នូវការការពារចំណែកដ៏សំខាន់នៃតំបន់អេកូព្រៃទឹកភ្លៀងតំបន់ជួរភ្នំក្រវាញជាទីកន្លែងអភិរក្សជីវចម្រុះដ៏សំខាន់ជាងគេមួយក្នុង ចំណោមទីកន្លែងអភិរក្សជីវចម្រុះដ៏សំខាន់ៗជាងគេទាំង ២០០ ទីតាំងនៅលើភពផែនដី ។ ដោយកំណត់តាមវិធីសាស្ត្រ ស្តង់ដា VCS តំបន់គណនេយ្យគម្រោងរេដបូកតំបន់ជួរភ្នំក្រវាញខាងត្បូងគឺមានទំហំ ៤៤២,៨៧១ ហិកតា ។ គម្រោង រេដបូកតំបន់ជួរភ្នំក្រវាញខាងត្បូងស្ថិតនៅផ្នែកនៃឧបទ្វីបឥណ្ឌូ-ភូមា គឺជាទីតាំងសំបូរដោយជីវចម្រុះដ៏សំខាន់មួយក្នុងចំណោមទីតាំងជីវចម្រុះសំខាន់ៗទាំង ៣៤ កន្លែង នៅលើពិភពលោក និងជាទីជម្រាលដ៏ចាំបាច់នៅឈូងសមុទ្រថៃ គ្របដណ្តប់ដោយគម្របព្រៃឈើប្រភេទផ្សេងៗគ្នា រួមមានទាំងព្រៃស្រោងពណ៌បៃតងជានិច្ច និងព្រៃស្រល់ខ្ពង់រាប រហូតដល់គម្របព្រៃតំបន់ទំនាប មានព្រៃស្នាច់តំបន់ដីសើម វាលស្មៅលិចទឹក បឹង និងព្រៃកោងកាងមាត់សមុទ្រ ។ គម្របព្រៃចម្រុះប្រភេទនេះគឺជាជម្រកសត្វដែលមានចំនួនយ៉ាងហោចណាស់ ៥២ ប្រភេទ យោងតាមបញ្ជីថនិកសត្វ បក្សី និងសត្វល្មូនដែលកំពុងរងគ្រោះជាសកល របស់អង្គការអាយ-យូ-ស៊ី-អិន ដែលក្នុងនោះ រួមមាន ក្រពើភ្នំ និងក្រុមសត្វដំរីអាស៊ីមួយហ្វូងអាចរស់នៅបាន ក្នុងចំណោមក្រុមហ្វូងសត្វដំរីកម្ពុជាទាំងពីរហ្វូង ។ តំបន់ទេសភាពនេះត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកជាឱកាសនៃការស្តារសត្វខ្លាធំផងដែរ ។

ដើម្បីជាការឆ្លើយតបទៅនឹងការគំរាមកំហែងដល់តំបន់ទេសភាពជួរភ្នំក្រវាញខាងត្បូង អង្គការសម្ព័ន្ធមិត្តសត្វព្រៃ ជាមួយនិងក្រសួងបរិស្ថាន (MOE) បានសម្រេចបង្កើតតំបន់ SCRP ។ ការការពារនៃ SCRP នឹងសម្រេចបានតាមរយៈការបន្ត និងបង្កើនការល្បាត នៅក្នុងតំបន់គម្រោង ក៏ដូចជាផ្តល់សកម្មភាពគម្រោងបន្ថែមដល់សហគមន៍ដែលត្រូវបានរៀបចំឡើងដើម្បីកាត់បន្ថយកត្តាជំរុញនៃការកាប់បំផ្លាញព្រៃឈើ។ សកម្មភាពសំខាន់របស់គម្រោងមានពីរ គឺការពង្រីកកសិកម្ម និងសហគមន៍អេកូទេសចរណ៍។ សកម្មភាពទាំងនេះនឹងជួយបង្កើនឱ្យមានសន្តិសុខផ្នែកហិរញ្ញវត្ថុនៅក្នុងសហគមន៍ ដូច្នេះមិន ចាំបាច់អនុវត្តការទាញយកធនធានដែលមិនមាននិរន្តរភាពចេញពីតំបន់គម្រោងទេ។ មូលនិធិក៏នឹងត្រូវបានផ្តល់ក្នុងការគាំទ្រអាហារូបករណ៍សម្រាប់កុមារមកពីសហគមន៍គម្រោង ដើម្បីដោះស្រាយនូវកត្តាជំរុញសំខាន់មួយនៃការកាប់បំផ្លាញព្រៃឈើ ដែលត្រូវបានកំណត់នៅក្នុងសិក្ខាសាលារបស់ភាគីពាក់ព័ន្ធ (ឧទាហរណ៍ដូចជា អត្រាការអប់រំទាប និងមានឱកាសតិចសម្រាប់ការអប់រំក្រោយថ្នាក់បឋមសិក្សា) ។ មូលនិធិនេះនឹងមានសម្រាប់សមាជិកសហគមន៍មកពីភូមិចំនួន ៨ បន្ថែមទៀតក្នុងឃុំចំនួន ៤ លើអ្នកដែលទទួលបានអត្ថប្រយោជន៍ផ្ទាល់ពីគម្រោងនេះ។ សកម្មភាពគម្រោងទាំងនេះបន្ថែមពីលើការកាត់បន្ថយកត្តាជំរុញនៃការកាប់បំផ្លាញព្រៃឈើ នឹងផ្តល់ការចូលរួមវិភាគទានក្នុងស្រុកយ៉ាងសំខាន់រហូតដល់ ១៥ នៃ ១៧ គោលដៅ អភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ (SDGs) និងជួយផ្តល់នូវអត្ថប្រយោជន៍យូរអង្វែងដល់សហគមន៍ និងជីវចម្រុះធម្មជាតិនៅក្នុងទីតាំងគម្រោង។

## ផលប្រយោជន៍លើភាគីពាក់ព័ន្ធ

| | |
|---|---|
| ផលប្រយោជន៍ទី១ | ប្រជាពលរដ្ឋថ្មីចំនួន ៤ គ្រួសារនៅឆាយអារ៉ែងបានចូលរួមជាមួយនឹងកម្មវិធីមីក្រូហិរញ្ញវត្ថុ |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលទទួលបានជាក់ស្តែង និងដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនលទ្ធភាពទទួលបានធនធានសេដ្ឋកិច្ច ដោយការផ្តល់នូវប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុ។ |

| | |
|---|---|
| ផលប្រយោជន៍ទី២ | ប្រជាពលរដ្ឋចំនួន ៧៥៣ គ្រួសារបានទទួលវគ្គបណ្តុះបណ្តាលនៃការបង្កើនប្រាក់ចំណូល ។ |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលត្រូវបានព្យាករណ៍ និងទទួលបានដោយផ្ទាល់ ។ |
| សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនលទ្ធភាពទទួលបានធនធានសេដ្ឋកិច្ច ដោយបានផ្តល់ការបណ្តុះបណ្តាលលើសកម្មភាពថ្មីនៃការបង្កើតប្រាក់ចំណូល ។ |

| | |
|---|---|
| ផលប្រយោជន៍ទី៣ | កិច្ចប្រជុំស្តីពីផែនការប្រើប្រាស់ដីធ្លីចំនួន ៦ លើក ត្រូវបានធ្វើឡើងជាមួយនឹងការចូលរួមនិងការគាំទ្រពីសំណាក់អាជ្ញាធរមូលដ្ឋាន ។ |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលទទួលបានជាក់ស្តែង និងដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនចំនួនគ្រួសារដែលទទួលបានសិទ្ធិពេញលេញក្នុងការប្រើប្រាស់ដីធ្លី |

| | |
|---|---|
| ផលប្រយោជន៍ទី៤ | ប្រជាពលរដ្ឋចំនួន ៣០៤ គ្រួសារបានឆ្លងកាត់ការបណ្តុះបណ្តាលផ្នែកកសិកម្ម |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលត្រូវបានព្យាករណ៍ និងទទួលបានដោយផ្ទាល់ ។ |

| | |
|---|---|
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនចំណេះដឹងអំពីការអនុវត្តល្អទៅលើផ្នែកកសិកម្ម វិធីសាស្ត្រក្នុងការជ្រើសរើសពូជដំណាំដែលល្អ និងទិន្នផលដំណាំខ្ពស់ ដើម្បីបង្កើតភាពធន់ និងកាត់បន្ថយហានិភ័យ ។ |

| | |
|---|---|
| ផលប្រយោជន៍ទី៥ | ប្រជាពលរដ្ឋចំនួន ៣០៤ គ្រួសារបានឆ្លងកាត់ការបណ្តុះបណ្តាលផ្នែកកសិកម្ម ។ |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលត្រូវបានព្យាករណ៍ និងទទួលបានដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនចំណេះដឹងអំពីការបណ្តុះបណ្តាលកសិកម្មលើវិធីសាស្រ្ត ឧបករណ៍និងពូជដំណាំដែលបានកែលម្អ ដើម្បីបង្កើនទិន្នផលដំណាំនិងទទួលបាននូវនិរន្តរភាព។ |

| | |
|---|---|
| ផលប្រយោជន៍ទី៦ | ដីគំរូកសិកម្មថ្មីចំនួន ០ ត្រូវបានបង្កើតនៅក្នុងតំបន់សហគមន៍; បច្ចុប្បន្នមានចំនួន ១ ឡូតិ៍ (បង្កើតកាលពីមុន) |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលត្រូវបានព្យាករណ៍ និងទទួលបានដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនចំណេះដឹងអំពីការបណ្តុះបណ្តាលកសិកម្មលើវិធីសាស្រ្ត ឧបករណ៍និងពូជដំណាំដែលបានកែលម្អ ដើម្បីបង្កើនទិន្នផលដំណាំនិងទទួលបាននូវនិរន្តរភាព។ |

| | |
|---|---|
| ផលប្រយោជន៍ទី៧ | ប៉ុស្តិ៍សុខភាព ១កន្លែង ត្រូវបានសាងសង់ និងបំពាក់ឧបករណ៍ ដើម្បីផ្តល់សេវាសុខភាពជូនសហគមន៍នៅក្នុងគម្រោង |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលត្រូវបានព្យាករណ៍ និងទទួលបានដោយផ្ទាល់ ។ |
| សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | លើកកម្ពស់លទ្ធភាពទទួលបានការផ្តល់សេវាសុខភាពជូនប្រជាពលរដ្ឋក្នុង សហគមន៍នៃគម្រោង ។ |

| | |
|---|---|
| ផលប្រយោជន៍ទី៨ | ផ្តល់ការងារជូនបុគ្គលិកសុខាភិបាលចំនួន ២រូប |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលត្រូវបានព្យាករណ៍ និងទទួលបានដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | លើកកម្ពស់លទ្ធភាពទទួលបានការផ្តល់សេវាសុខភាពជូនប្រជាពលរដ្ឋក្នុងសហគមន៍នៃគម្រោង ។ |

| | |
|---|---|
| ផលប្រយោជន៍ទី៩ | និស្សិតចំនួន៧រូបទទួលបានអត្ថប្រយោជន៍អាហារូបករណ៍សម្រាប់ការអប់រំកម្រិតឧត្តមសិក្សា រួមទាំងសាកលវិទ្យាល័យផងដែរ ។ |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលទទួលបានជាក់ស្តែង និងដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនឱកាសទទួលបានការអប់រំសម្រាប់យុវជន ដែលនាំឱ្យមានការលើកកម្ពស់សមត្ថភាពបុគ្គលនៅក្នុងសហគមន៍គម្រោង ។ |

| | |
|---|---|
| ផលប្រយោជន៍ទី១០ | ការចូលរួមរបស់ស្ត្រីមានចំនួន ៣៧.៥% នៅក្នុងកម្មវិធីអាហារូបករណ៍សម្រាប់ការអប់រំ និងគម្រោងដំណើរការនៃវិស័យអប់រំ។ |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលត្រូវបានព្យាករណ៍ និងទទួលបានដោយផ្ទាល់ ។ |
| សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | កាត់បន្ថយវិសមភាពសម្រាប់ស្ត្រីក្នុងឱកាសការងារ ទទួលបានការអប់រំ និងភាពជាអ្នកដឹកនាំ |

| | |
|---|---|
| ផលប្រយោជន៍ទី១៣ | ៥៧% នៃអ្នកចូលរួមក្នុងការប្រជុំសហគមន៍ជាស្ត្រី។ ប្រហែល ៥០ ភាគរយនៃអ្នកចូលរួមក្នុងសកម្មភាពមីក្រូហិរញ្ញវត្ថុនិងសកម្មភាពបង្កើតប្រាក់ចំណូលគឺជាស្ត្រី ។ |

| | |
|---|---|
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលទទួលបានជាក់ស្តែង និងដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង ក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគត និងរដ្ឋាភិបាល ឬអាជ្ញាធរ ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងសកម្មភាពគម្រោង និងកាត់បន្ថយវិសមភាពសម្រាប់ស្ត្រីក្នុងឱកាសការងារនិងភាពជាអ្នកដឹកនាំ |

| | |
|---|---|
| ផលប្រយោជន៍ទី១៤ | ៥.៤% នៃនិយោជិតក្នុងគម្រោងគឺជាស្ត្រី |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលទទួលបានជាក់ស្តែង និងដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង ក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគត និងរដ្ឋាភិបាល ឬអាជ្ញាធរ ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនឱកាសការងាររបស់ស្ត្រីនៅក្នុងគម្រោង និងកាត់បន្ថយវិសមភាពសម្រាប់ស្ត្រីក្នុងឱកាស ការងារ និងភាពជាអ្នកដឹកនាំ |

| | |
|---|---|
| ផលប្រយោជន៍ទី១៥ | ប្រជាពលរដ្ឋចំនួន ៣០៤ គ្រួសារបានឆ្លងកាត់ការបណ្តុះបណ្តាលផ្នែកកសិកម្ម |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលត្រូវបានព្យាករណ៍ និងទទួលបានដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង ក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនការប្រើប្រាស់វិធីសាស្ត្រកសិកម្ម ឧបករណ៍ និងពូជដំណាំដែលបានកែលម្អ ដើម្បីបង្កើន ទិន្នផលដំណាំនិងនិរន្តរភាព ដែលនឹងជួយដល់ការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាព ។ |

| | |
|---|---|
| ផលប្រយោជន៍ទី១៧ | ប្រជាពលរដ្ឋថ្មីចំនួន ៤ គ្រួសារបានចូលរួមជាមួយនឹងកម្មវិធីមីក្រូហិរញ្ញវត្ថុ ។ ១០០% នៃអ្នកចូលរួមជាមួយនឹងកម្មវិធីមីក្រូហិរញ្ញវត្ថុគឺជាស្ត្រី ។ |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលទទួលបានជាក់ស្តែង និងដោយផ្ទាល់ ។ |

| | |
|---|---|
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនការចុះបញ្ជីអាជីវកម្មជាផ្លូវការ និងការរីកលូតលាស់នៃសហគ្រាសខ្នាតតូច និងមធ្យម នៅក្នុងសហគមន៍នៃតំបន់គម្រោង និងធានាបាននូវលទ្ធភាពទទួលបានហិរញ្ញវត្ថុប្រកបដោយសមធម៌សម្រាប់ស្ត្រី ។ |

| | |
|---|---|
| ផលប្រយោជន៍ទី១៨ | ប្រជាពលរដ្ឋចំនួន ៧៥៣ គ្រួសារបានទទួលវគ្គបណ្តុះបណ្តាលនៃការបង្កើតប្រាក់ចំណូល។ ប្រហែល ៤១% នៃអ្នកចូលរួមសរុបនៃសកម្មភាពនេះគឺជាស្ត្រី។ |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលត្រូវបានព្យាករណ៍ និងទទួលបានដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនការបង្កើតការងារ សហគ្រិនភាព និងការច្នៃប្រឌិតនៅក្នុងសហគមន៍តំបន់គម្រោងនិងធានាបាននូវការទទួលបានហិរញ្ញវត្ថុប្រកបដោយសមធម៌សម្រាប់ស្ត្រី |

| | |
|---|---|
| ផលប្រយោជន៍ទី១៩ | ប្រជាពលរដ្ឋថ្មីចំនួន ២០ គ្រួសារបានចូលរួមក្នុងសកម្មភាពអេកូទេសចរណ៍ (CBET) |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលទទួលបានជាក់ស្តែង និងដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនចំនួនគ្រួសារដែលបានចូលរួមក្នុងសកម្មភាពអេកូទេសចរណ៍ និងទទួលប្រាក់ចំណូល |

| | |
|---|---|
| ផលប្រយោជន៍ទី២០ | ចំនួនភ្ញៀវទេសចរណ៍សរុបចំនួន ៨,៥៩០នាក់ បានមកទស្សនាកន្លែងអេកូទេសចរណ៍សហគមន៍(CBET)<br>ជីផាត៖ ភ្ញៀវទេសចរណ៍ចំនួន ៥,០៣០នាក់ នៅជីផាត [៣,៤៤៧នាក់ ជាភ្ញៀវទេសចរណ៍ជាតិ និង១,៥៨៣នាក់ ជាភ្ញៀវទេសចរណ៍អន្តរជាតិ]<br>ឆាយអារ៉ែង៖ ភ្ញៀវទេសចរណ៍ចំនួន ៣,៥៦០នាក់ នៅឆាយអារ៉ែង [៣,១៨៨នាក់ ជាភ្ញៀវទេសចរណ៍ជាតិ និង១៨៦នាក់ ជាភ្ញៀវទេសចរណ៍អន្តរជាតិ] |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលទទួលបានជាក់ស្តែង និងដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនចំនួនភ្ញៀវទេសចរណ៍មកទស្សនាគម្រោង និងសកម្មភាពអេកូទេសចរណ៍ |

| | |
|---|---|
| ផលប្រយោជន៍ទី២១ | ប្រជាពលរដ្ឋថ្មីចំនួន ៤ គ្រួសារ (ចំនួនសរុប ៧៥ គ្រួសារ) នៅឆាយអារ៉ែងបានចូលរួមជាមួយនឹងកម្មវិធីមីក្រូហិរញ្ញវត្ថុ ។ ១០០% នៃអ្នកចូលរួមជាមួយនឹងកម្មវិធីមីក្រូហិរញ្ញវត្ថុ គឺជាស្ត្រី ។ |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលទទួលបានជាក់ស្តែង និងដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនលទ្ធភាពទទួលបានឥណទានមានតម្លៃសមរម្យនៅក្នុងសហគមន៍នៃតំបន់គម្រោង |

| | |
|---|---|
| ផលប្រយោជន៍ទី២២ | ប្រជាពលរដ្ឋចំនួន ៣០៤ គ្រួសារបានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកកសិកម្ម |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលត្រូវបានព្យាករណ៍ និងទទួលបានដោយផ្ទាល់ ។ |

| | |
|---|---|
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | តំបន់សហគមន៍នៃគម្រោង ក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | តាមរយៈវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រកសិកម្មដែលបានកែលម្អ នឹងបង្កើនប្រសិទ្ធភាពការប្រើប្រាស់ធនធាន និងការផ្តោតសំខាន់លើអនាម័យ បរិស្ថានស្អាត និង បច្ចេកទេសក្នុងវិស័យកសិកម្មក្នុងសហគមន៍តំបន់គម្រោង |

| | |
|---|---|
| ផលប្រយោជន៍ទី២៣ | ដីឡូត៍កសិកម្មគំរូថ្មីចំនួន ០ ត្រូវបានបង្កើតនៅក្នុងតំបន់សហគមន៍; បច្ចុប្បន្នមានចំនួន ១ ឡូតិ៍ (បង្កើតកាលពីមុន) |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលត្រូវបានព្យាករណ៍ និងទទួលបានដោយផ្ទាល់ ។ |
| សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | តាមរយៈការអនុវត្តសួនកសិកម្មគំរូនេះ នាំឱ្យមានការកើនឡើងនៃប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធាន និងការផ្តោតសំខាន់លើអនាម័យ បរិស្ថានស្អាត និង បច្ចេកទេសក្នុងវិស័យកសិកម្ម ក្នុងសហគមន៍តំបន់គម្រោង ។ |

| | |
|---|---|
| ផលប្រយោជន៍ទី២៤ | ៥៧% នៃអ្នកចូលរួមក្នុងកិច្ចប្រជុំសហគមន៍គឺជាស្ត្រី។ ប្រហែល ៦៧% នៃអ្នកចូលរួមផ្នែកមីក្រូហិរញ្ញវត្ថុ និងបង្កើតប្រាក់ចំណូលគឺជាស្ត្រី។ |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលទទួលបានជាក់ស្តែង និងដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | តំបន់សហគមន៍នៃគម្រោង ក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគត និងរដ្ឋាភិបាលឬអាជ្ញាធរ ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | ការបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងសកម្មភាពគម្រោងនិងកាត់បន្ថយវិសមភាពសម្រាប់ស្ត្រីក្នុងឱកាសការងារនិងភាពជាអ្នកដឹកនាំ។ |

| | |
|---|---|
| ផលប្រយោជន៍ទី២៥ | កិច្ចប្រជុំស្តីពីផែនការប្រើប្រាស់ដីធ្លីចំនួន ៦ លើក ជាមួយនឹងការចូលរួម និងគាំទ្រពីសំណាក់អាជ្ញាធរមូលដ្ឋាន |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលត្រូវបានព្យាករណ៍ និងទទួលបានដោយផ្ទាល់ ។ |

| | |
|---|---|
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | តំបន់សហគមន៍នៃគម្រោង ក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនចំនួនគ្រួសារដែលមានសិទ្ធិកាន់កាប់ដីធ្លីប្រកបដោយសុវត្ថិភាពនិងក្នុងផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួមនិងប្រកបដោយនិរន្តរភាព |

| | |
|---|---|
| ផលប្រយោជន៍ទី២៦ | ប្រជាពលរដ្ឋចំនួន ៣,២៤១នាក់ បានយល់ដឹងតាមរយៈការផ្សព្វផ្សាយ និងការបញ្ជ្រាបចំណេះដឹង។ |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលទទួលបានជាក់ស្តែង និងដោយផ្ទាល់ ។ |
| សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនការយល់ដឹងអំពីការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងន័យជួយថែរក្សាបរិស្ថាន និងការការពារសត្វព្រៃក្នុងសហគមន៍នៃតំបន់គម្រោង។ |

| | |
|---|---|
| ផលប្រយោជន៍ទី២៧ | ប្រជាពលរដ្ឋថ្មីចំនួន ២០ គ្រួសារកំពុងចូលរួមក្នុងសកម្មភាពអេកូទេសចរណ៍(CBET) |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលទទួលបានជាក់ស្តែង និងដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនចំនួនគ្រួសារដែលបានចូលរួមក្នុងសកម្មភាពអេកូទេសចរណ៍ និងទទួលប្រាក់ចំណូល |

| | |
|---|---|
| ផលប្រយោជន៍ទី២៨ | ភ្ញៀវទេសចរសរុបចំនួន ៨,៥៩០ នាក់ បានមកទស្សនាកន្លែងអេកូទេសចរណ៍សហគមន៍ (CBET)<br>ជីផាត៖ ភ្ញៀវទេសចរចំនួន ៥,០៣០នាក់ នៅជីផាត [៣,៤៤៧នាក់ ជាភ្ញៀវទេសចរណ៍ជាតិ និង ១,៥៨៣នាក់ ជាភ្ញៀវទេសចរណ៍អន្តរជាតិ]<br>ឆាយអារ៉ែង៖ ភ្ញៀវទេសចរចំនួន ៣,៥៦០នាក់ នៅឆាយអារ៉ែង [៣,១៨៨នាក់ ជាភ្ញៀវទេសចរជាតិ និង ១៨៦នាក់ ជាភ្ញៀវទេសចរអន្តរជាតិ] |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលទទួលបានជាក់ស្តែង និងដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនចំនួនភ្ញៀវទេសចរមកទស្សនា សកម្មភាពអេកូទេសចរណ៍ក្នុងគម្រោង |

| | |
|---|---|
| ផលប្រយោជន៍ទី២៩ | ផ្ទៃដីព្រៃទំហំ ២១,០៦០ ហិកតា ត្រូវបានការពារពីការបាត់បង់ព្រៃឈើនៅក្នុងតំបន់គម្រោង |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលទទួលបានជាក់ស្តែង និងដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | តាមរយៈការការពារព្រៃឈើតំបន់គម្រោងនេះ នឹងធ្វើឱ្យមានការកើនឡើងនូវកម្រិតភាពធន់ និងភាពបន្សាំខ្លួនទៅនឹងគ្រោះថ្នាក់ដែលបង្កដោយកត្តាអាកាសធាតុ ឬគ្រោះធម្មជាតិផ្សេងៗ ។ |

| | |
|---|---|
| ផលប្រយោជន៍ទី៣១ | ប្រជាពលរដ្ឋចំនួន ៣,២៤១នាក់ បានយល់ដឹងតាមរយៈការផ្សព្វផ្សាយ និងការបញ្ជ្រាបចំណេះដឹង។ |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលត្រូវបានព្យាករណ៍ និងទទួលបានដោយផ្ទាល់ ។ |

| | |
|---|---|
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត និងរដ្ឋាភិបាល ឬអាជ្ញាធរ ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | លើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ការអភិរក្ស ការបង្កើនសមត្ថភាពក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ |

| | |
|---|---|
| ផលប្រយោជន៍ទី៣៣ | កិច្ចប្រជុំស្តីពីផែនការប្រើប្រាស់ដីធ្លីចំនួន ៦លើក ជាមួយនឹងការចូលរួម និងការគាំទ្រពីសំណាក់អាជ្ញាធរមូលដ្ឋាន ។ |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលត្រូវបានព្យាករណ៍ និងទទួលបានដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត និងរដ្ឋាភិបាល ឬអាជ្ញាធរ ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | ផ្សព្វផ្សាយការគ្រប់គ្រងតំបន់ព្រៃឈើប្រកបដោយនិរន្តរភាព ។ |

| | |
|---|---|
| ផលប្រយោជន៍ទី៤០ | ក្រុមល្បាតនៃកម្មវិធីការពារព្រៃឈើតំបន់ជួរភ្នំក្រវាញខាងត្បូងបានចងក្រងសំណុំរឿងទាក់ទងនឹងបទល្មើសព្រៃឈើចំនួន ២១៩ ករណី (រួមមាន ៥១ករណី ត្រូវបានបញ្ជូនទៅតុលាការ និង ១៦៨ករណី ជាករណីពិន័យអន្តរការណ៍) ។ |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលទទួលបានជាក់ស្តែង និងដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត និងរដ្ឋាភិបាល ឬអាជ្ញាធរ ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | កាត់បន្ថយការកាប់ឈើ និងការបរបាញ់សត្វព្រៃខុសច្បាប់នៅក្នុងតំបន់គម្រោង។ |

| | |
|---|---|
| ផលប្រយោជន៍ទី៤១ | ប្រជាពលរដ្ឋថ្មីចំនួន ៤ គ្រួសារនៅឆាយអារ៉ែងបានចូលរួមជាមួយនឹងកម្មវិធីមីក្រូហិរញ្ញវត្ថុ ។ ១០០% នៃអ្នកចូលរួមជាមួយនឹងកម្មវិធីមីក្រូហិរញ្ញវត្ថុគឺជាស្ត្រី ។ |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលត្រូវបានព្យាករណ៍ និងទទួលបានដោយផ្ទាល់ ។ |

| | |
|---|---|
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | ជំរុញឱ្យមានការវិនិយោគ និងមីក្រូហិរញ្ញវត្ថុ ដើម្បីបង្កើនការអភិវឌ្ឍប្រកបដោយចីរភាព ។ |

| | |
|---|---|
| ផលប្រយោជន៍ទី៤២ | ប្រជាពលរដ្ឋចំនួន ៣០៤ គ្រួសារបានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកកសិកម្ម ។ |
| ប្រភេទនៃផលប្រយោជន៍ | នេះគឺជាផលវិជ្ជមានមួយដែលទទួលបានជាក់ស្តែង និងដោយផ្ទាល់ ។ |
| ក្រុមអ្នកពាក់ព័ន្ធដែលទទួលផល | សហគមន៍នៅក្នុងទីតាំងគម្រោង នាពេលបច្ចុប្បន្ន និងទៅពេលអនាគត ។ |
| ការផ្លាស់ប្តូរលទ្ធផលនៅក្នុងសុខុមាលភាព | បង្កើនការយល់ដឹងនៅក្នុងសហគមន៍នៃតំបន់គម្រោងអំពីការអភិវឌ្ឍប្រកបដោយនិរន្តរភាពក្នុងន័យជួយថែរក្សាបរិស្ថាន និងការការពារសត្វព្រៃក្នុងសហគមន៍នៃតំបន់គម្រោង ។ |